# កម្មវិធីសិក្សាប្រវត្តិវិទ្យា នៃប្រទេសកម្ពុជា
# សំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅ RULE
# ចំនួន 45 h = 3ក្រេឌីត

## កម្មវត្ថុ និងគោលបំណង :

ការសិក្សាមុខវិជ្ជានេះ មានគោលបំណងចង់ឱ្យនិសិ្សតយល់ដឹង ស្គាល់សាវតាសង្គម សេដ្ឋកិច្ច ទំនៀមទំលាប់ ពូជសាសន៍ របស់ខ្លួនឱ្យបានច្បាស់លួ ថាតើយើងជានរណា ? មកពីណា ? ទៅណា ? ត្រូវសំរេចចិត្តធ្វើយ៉ាងណា ? ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រទេសជាតិ។ មិនតែប៉ុណ្ណោះមុខវិជ្ជានេះ មានបំណងចង់ឱ្យនិសិ្សត ស្វែងយល់អំពីការវិវត្តន៏ នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។

ម្យ៉ាងវិញទៀត ក្រោយពីបញ្ចប់ការសិក្សា និសិ្សតអាច :

- មានសមត្ថភាព ជំនាញក្នុងការវិភាគ និង ការដោះស្រាយបញ្ហា ហើយមានបំណិតក្នុងការទំនាក់ទំនង ពតិមាន និង ផ្តុំយោបល់ ហើយអាចរៀបចំជាផែនការសកម្មភាពនានា ។

- មានសមត្ថភាពថ្លឹងថ្លែង និងមានការទទួលខុសត្រូវខ្ពស់ក្នុងផ្នែក សីលធមិ ចរិយាធមិ និងស្វែងយល់អំពីផ្លូវជីវិត និងប្រទេសជាតិយ៉ាងពិតប្រាកដ ។

- ធ្វើឱ្យនិសិ្សតទាំងអស់យល់ ហើយទទួលស្គាល់តម្លៃវប្បធមិខ្មែរ ដែលធ្លាប់ជាអរិយធមិដ៏ខ្ពង់ខ្ពស់លើពិភពលោក ជាសម័យដើម ហើយព្រមទាំងប្រយោជន៏ឱ្យពួកគេស្រលាញ់ ចេះថែរក្សា ការពារប្រទេសជាតិខ្លួន ដោយខ្លួនឯង ។

| ល.រ | ខ្លឹមសារប្រវត្តិសាស្ត្រខ្មែរ | ចំនួនម៉ោង | ផ្សេងៗ |
|---|---|---|---|
| 1 | **<u>សម័យនគរភ្នំ ឬហ្វូណន</u>**<br>-ឥណ្ឌាកម្ម និង កំណើតរដ្ឋ<br>-រាជវង្សនគរភ្នំ<br>-វិស័យរដ្ឋបាល<br>-វិស័យវប្បធមិ និង សាសនា<br>-វិស័យសង្គម<br>-បណ្តាបទពិសោធន៏ប្រវត្តិសាស្ត្រ សម័យនគរភ្នំលើការគ្រប់គ្រងរដ្ឋ | **3 h** | |
| 2 | **<u>ព្រះរាជាណាចក្រកម្ពុជាសម័យចេនឡា</u>**<br>-ការកកើតរដ្ឋចេនឡា<br>-រាជវង្សានុវង្សចេនឡា<br>-ចេនឡាដីគោក និង ចេនឡាទឹកលិច<br>-ចេនឡាក្រោមការគ្រប់គ្រងបរទេស នៃអំណាចត្រួតត្រា របស់ជ្វា<br>-បណ្តាបទពិសោធន៏សម័យកាលចេនឡា លើការគ្រប់គ្រងរដ្ឋ | **3 h** | |

| | | | |
|---|---|---|---|
| | ជីវភាពរស់របស់ប្រជាពលរដ្ឋ<br>- ចលនារើបំរះរំដោះទឹកដី ក្រោមការដឹកនាំដ៏ឈ្លាសវៃ នៃ ព្រះរាជាខ្មែរ | | |
| 3 | **ព្រះរាជាណាចក្រកម្ពុជាសម័យអង្គរ**<br>+**ការស្តារប្រទេសឡើងវិញ ក្រោយសង្គ្រាម និងការកសាងរាជធានី**<br>- ស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី២ ក្នុងការរៀបចំប្រទេសជាតិ<br>- មូលដ្ឋានគ្រឹះ នៃព្រះរាជាខ្មែរ ព្រមទាំងលក្ខណៈសម្គាល់របស់ទ្រង់ ក្នុងការស្ថាបនាជាតិ<br>- ការកសាងរាជធានីអង្គរ ក្នុងរាជ្យព្រះបាទយសោវរ្ម័ន | **3 h** | |
| | +**អភិវឌ្ឍន៍នៃព្រះរាជាណាចក្រកម្ពុជាសម័យអង្គរ**<br>- ការបង្រួបបង្រួមរាជវង្សខ្មែរ និងការកសាងប្រទេស<br>- រាជវង្សសូរ្យវរ្ម័នទី១ និងការកសាងអង្គរដំណាក់កាល ទី២<br>- ចលនាបះបោរក្នុងប្រទេស និងសង្គ្រាមជាមួយបរទេស | **3 h** | |
| | +**ព្រះបាទជ័យវរ្ម័នទី៧ និងភាពរុងរឿងនៃចក្រភពខ្មែរ**<br>- អភិវឌ្ឍន៍វប្បធម៌ និងសេដ្ឋកិច្ច<br>- វីរភាពព្រះបាទជ័យវរ្ម័នទី៧ និងព្រះរាជអគ្គមហេសី<br>- ធនធានមនុស្ស និងបណ្តាមតិកពីអតីតកាល | **3 h** | |
| | +**ស្ថាប័នដឹកនាំសម័យអង្គរ**<br>- វិស័យនយោបាយក្រៅ និងក្នុងប្រទេស<br>- លទ្ធិទេវរាជ និងពុទ្ធរាជ<br>- វិស័យអប់រំសិក្សា | **3 h** | |
| | +**គ្រាដំបូងនៃការធ្លាក់ចុះសម័យអង្គរ**<br>- ទិដ្ឋភាពផ្នែកក្រៅ នៃការកកើតរដ្ឋថ្មី និងការដកថយ ពីដែនដីអាណានិគមរបស់ខ្លួន<br>- ទិដ្ឋភាពនយោបាយក្នុងប្រទេស<br>- ការរងគ្រោះពីការឈ្លានពានពីបរទេស និងដំណោះចុងក្រោយ | **3 h** | |
| 4 | **ព្រះរាជាណាចក្រកម្ពុជា សម័យចតុម្មុខ**<br>- រជ្ជកាលព្រះបាទពញាយ៉ាត | **3 h** | |

| | | | |
|---|---|---|---|
| | -ស្ថានភាពក្រោយពេលតាំរាជធានីនៅចតុម្មុខ<br>-ផលវិបាកសង្គ្រាមរវាងអង្គច័ន្ទរាជា និងស្តេចកន | | |
| 5 | **<u>ព្រះរាជាណាចក្រកម្ពុជា</u>  <u>សម័យលង្វែក</u>**<br>-ការកសាងបន្ទាយលង្វែក<br>-ការបាក់បែកបន្ទាយលង្វែក<br>-កម្ពុជាក្រោយការបែកបាក់បន្ទាយលង្វែក | **3 h** | |
| 6 | **<u>ព្រះរាជាណាចក្រកម្ពុជា</u>  <u>សម័យឧត្តុង</u>**<br>-ស្ថានភាពកម្ពុជា នៅសតវត្សទី១៨<br>-ដំណាក់កាលទី១ សម័យឧត្តុង<br>-វិបត្តដណ្តើមរាជសម្បត្តិ ក្នុងព្រះរាជវង្សានុវង្សខ្មែរ<br>-ការបាត់បង់ទឹកដី និងការទន្ទ្រានយកទឹកដីខ្មែរ  ពីសំណាក់បរទេស | **3 h** | |
| 7 | **<u>ព្រះរាជាណាចក្រកម្ពុជា</u>  <u>សម័យអាណាព្យាបាល</u>**<br>-ស្ថានភាពព្រះរាជាណាចក្រកម្ពុជានៅដើមសតវត្ស  ទី១៩<br>-អំពើរបស់បារាំងមកលើកម្ពុជាមុនឆ្នាំ ១៨៦៣<br>-កិច្ចព្រមព្រៀងបារាំង.ខ្មែរ និងបណ្តាសន្ធិសញ្ញា  ដទៃទៀត | **3 h** | |
| | **<u>ស្ថានភាពព្រះរាជាណាចក្រកម្ពុជាក្នុងរាជ</u>  :**<br>-ព្រះបាទនរោត្តម<br>-ព្រះបាទស៊ីសុវត្ថ<br>-ព្រះបាទមុនីវង្ស<br>-ព្រះបាទនរោត្តមសីហនុ | **3 h** | |
| 8 | **<u>ព្រះរាជាណាចក្រកម្ពុជា</u>  <u>សម័យសង្គមរាស្ត្រនិយម</u>**<br>-ព្រះរាជបូជនីយកម្មរបស់ សម្តេចនរោត្តនសីហនុ ដើម្បីទាមទារឯករាជ្យ ជូន ប្រទេសកម្ពុជា | **3 h** | |
| | **សមិទ្ធផលសង្គមរាស្ត្រនិយម  ក្រោមព្រះរាជកិច្ចដឹកនាំ របស់សម្តេចនរោត្តមសីហនុ** | **3 h** | |
| | **រំលឹកមេរៀនត្រៀមប្រលង** | **3 h** | |

**ឯកសារយោង**

- ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា អង្គការបោះពុម្ពផ្សាយ ប្រូប្រ៉ោស្ស ១៩៨៥ កែសំរួលដោយបណ្ឌិត ឡុង សៀម

-កម្រងប្រវត្តិសាស្ត្រ ព្រះរាជាណាចក្រ កម្ពុជា 2003 ដោយ សាស្ត្រាចារ្យ ឥន្ទ ឱមសាម៉េង

-ប្រវត្តិសាស្ត្រខ្មែរ បណ្ឌិត រស់ ចន្ត្រាបុត្រ ១៩៩៧

-ប្រវត្តិសាស្ត្រខ្មែរ ដោយសាស្ត្រាចារ្យ ត្រឹង ងា  ភ្នំពេញ 1973 ភាគ ១ និង ភាគ២  ១៩៧៣

# Course Assessment

| | |
|---|---|
| **- Attendants** | **10%** |
| **- Assignment** | **15%** |
| **- Midterm** | **25%** |
| **- Final Examine** | **50%** |